**ប្រការ ៨** : លិខិតអនុញ្ញាតអោយប្រើប្រាស់អាវុធ និង ជាតិផ្ទុះគ្រប់ប្រភេទ មានសុពលភាព ១ ឆ្នាំ ចាប់ពីថ្ងៃចេញលិខិតអនុញ្ញាតអោយប្រើប្រាស់អាវុធ និងជាតិផ្ទុះនេះ ។

លិខិតអនុញ្ញាតអោយប្រើប្រាស់អាវុធ និង ជាតិផ្ទុះគ្រប់ប្រភេទចាស់មានសុពលភាពដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩៦ ។

**ប្រការ ៩** : នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ អគ្គសេនាធិការ និង គ្រប់ស្ថាប័នក្រោមឱវាទ ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ អភិបាលខេត្ត – ក្រុង មេបញ្ជាការយោធភូមិភាគ មេបញ្ជាការតំបន់ប្រតិបត្តិសឹករង ស្នងការនគរបាលខេត្ត–ក្រុង ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ

| សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | សហរដ្ឋមន្ត្រីក្រសួងការពារជាតិ |
|---|---|
| ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **ស ខេង យូ ហុកគ្រី** | **ទៀ បាញ់ ទា ចំរ៉ាត់** |

* * *

## ២ - អន្តរក្រសួង សាធារណការ និងដឹកជញ្ជូន សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មហាផ្ទៃ

រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ១៩៩៦

**ប្រកាសរួមលេខ : ២៨១ ប្រក.សក**

**ស្តីពីការបន្តផ្តល់ផ្លាកលេខរថយន្ត ចន្លោតស្តាំ**

**អន្តរក្រសួង សាធារណការ និង ដឹកជញ្ជូន**

**សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ - មហាផ្ទៃ**

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ១១-១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិ បាលកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០-៩៤/៩០ ចុះថ្ងៃទី ៣១ ១០-១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញសេចក្តីជូនដំណឹងលេខ ៣៨៧ សជណ.ពហ ចុះថ្ងៃទី ០១ ១០-១៩៩៣ របស់ ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការបញ្ឈប់ការនាំចូល រថយន្តចង្កូតស្តាំ ។
- បានឃើញលិខិតលេខ ១៦៩៥ សជណ.គម ចុះថ្ងៃទី ១៧-១០-១៩៩៤ របស់ទីស្តីការគណៈ រដ្ឋមន្ត្រី ស្តីអំពីករណីនាំចូលរថយន្តចង្កូតស្តាំ ។
- បានឃើញសេក្តីជូនដំណឹងលេខ ០១៤ សក ចុះថ្ងៃទី ១៣-៧-៩៥ របស់ក្រសួងសាធារណការ និង ដឹកជញ្ជូន ស្តីពីការយល់ផ្តល់ផ្លាកលេខ រថយន្តចង្កូតស្តាំ ។
- យោងតាមសំណូមពរ របស់ម្ចាស់យានយន្តចង្កូតស្តាំមួយចំនួនដែលមិន បានដាក់ពាក្យសុំផ្តល់ ផ្លាកលេខទាន់ពេលកំណត់ ។

**សំរេច**

**ប្រការ ១** : រថយន្តចង្កូតស្តាំដែលម្ចាស់រថយន្តបានបង់ពន្ធរួច អនុញ្ញាតអោយមកធ្វើផ្លាក លេខសំគាល់រថយន្តនៅក្រសួងសាធារណការ និង ដឹកជញ្ជូន ក្នុងរយៈពេល ៦០ ថ្ងៃ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខាលើប្រកាសរួមនេះ ។

**ប្រការ ២** : ផុតរយៈពេលកំណត់ខាងលើ ក្រសួងសាធារណការ និង ដឹកជញ្ជូន មិន ទទួលខុសត្រូវក្នុងការផ្តល់ផ្លាកលេខជូនរថយន្តចង្កូតស្តាំទៀតឡើយ ហើយ ម្ចាស់រថយន្តត្រូវទទួលខុសត្រូវនៅចំពោះមុខក្រសួងមានសមត្ថកិច្ច ។

**ប្រការ ៣** : លោកអគ្គនាយក នៃក្រសួងសាធារណការ និង ដឹកជញ្ជូន លោកអគ្គនាយក នគរបាលជាតិនៃក្រសួងមហាផ្ទៃ លោកនាយកទីចាត់ការគយ និង រដ្ឋាករ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លោកនាយកមន្ទីរសាធារណការ និង

ដឹកជញ្ជូន ខេត្ត-ក្រុងមានភារកិច្ច អនុវត្តតាមសេចក្តីប្រកាសរួមចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

| | | |
|---|---|---|
| សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ទេសរដ្ឋមន្ត្រី | ឧបនាយករដ្ឋមន្ត្រី |
| ហត្ថលេខា និង ត្រា | រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច | រដ្ឋមន្ត្រីក្រសួងសាធារណការ |
| ស ខេង យូ ហុកគ្រី | និងហិរញ្ញវត្ថុ | និងដឹកជញ្ជូន |
| | ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| | គាត ឈន់ | អ៊ឹង គៀត |

* * *

# ៣ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

## ប្រកាស

**ប្រកាសលេខ ៤៥៩ ប្រក.ឧក រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ១៩៩៦**

**ប្រការ ១** : អនុញ្ញាតអោយក្រុមហ៊ុន សាន់ ឌី កូអែលធីឌី ( SANDY CO.LTD ) តំណាង ដោយលោក **ជា សាន** ជនជាតិខ្មែរ អាយុ ៥១ ឆ្នាំ ភេទ ប្រុស អាស័យដ្ឋានផ្ទះលេខ ៧៣ E0 ផ្លូវ លេខ ១៣០ សង្កាត់ផ្សារថ្មីទី ៣ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កាន់អត្តសញ្ញាណប័ណ្ណ លេខ ១៤៦៣៣២ ភព ចុះថ្ងៃទី ២៩-៣-៨៩ បង្កើត « រោងចក្រផ្លាស្ទិក » ដែលមានឈ្មោះ « រោងចក្រផ្លាស្ទិក សាន់ ឌី » មានទីតាំងស្ថិតនៅភូមិចុងថ្នល់ សង្កាត់ទឹកថ្លា ខ័ណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ។

**ប្រការ ២** : ការបង្កើតរោងចក្រនេះត្រូវធ្វើទៅតាមប្លង់ និង គំរោងសិក្សាលទ្ធភាពបង្កើតរោងចក្រផ្លាស្ទិក ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។